# ជួបរ៉ាអៃរី មកពីប្រទេសតាហ៊ីទី

ជួបកុមារបឋមសិក្សាកំពុងជួយមនុស្សដទៃ
ដូចព្រះគ្រីស្ទបានធ្វើ ។



រ៉ាអៃរីនៅលើដើមសាកេ

## រឿងទាំងអស់អំពីរ៉ាអៃរី



**ភាសា ៖** បារាំង

**អាយុ ៖** ៩ ឆ្នាំ

**មកពី ៖** ប្រទេសតាហ៊ីទី



**គោលដៅ និងក្ដីសុបិន ៖**
១) រៀនលេងព្យាណូ ។
២) អានព្រះគម្ពីរមរមនទាំងមូល ។
៣) ក្លាយជាវេជ្ជបណ្ឌិត ឬអ្នកបើកយន្តហោះម្នាក់ ។

**គ្រួសារ ៖** ម៉ាក់ ប៉ា
បងប្អូនប្រុសបីនាក់ និងប្អូនស្រីម្នាក់



គំនូរលម្អដោយ ម៉ាធីវ ហ្វៀរ



## ដៃជំនួយរបស់រ៉ាអៃរី

រ៉ាអៃរីចូលចិត្តទៅលេងលោកយាយរបស់គាត់ឈ្មោះ ម៉ាមី ។ គាត់អាចលេងនៅឆ្នេរសមុទ្រ ហើយចាប់ត្រីនៅក្នុងល្អាងទឹកសមុទ្រ ។ គាត់បេះផ្លែស្វាយ និងចេកពីដើមមកហូប ។ កាលពីពីរបីឆ្នាំមុន គាត់បានជួបមិត្តរបស់ម៉ាមី ឈ្មោះកាលី និងមៃ ។

ជារៀងរាល់ព្រឹក រ៉ាអៃរី និងម៉ាមីអានព្រះគម្ពីរមរមនជាមួយគ្នា ។ កាលី និងមៃបានចាប់ផ្ដើមអាននឹងពួកគេដែរ ។ រ៉ាអៃរីបានជួយពន្យល់បទគម្ពីរ ដើម្បីឲ្យងាយយល់ដល់ពួកគាត់ ។

រ៉ាអៃរី និងបងប្អូនប្រុសគាត់ចូលចិត្តជួយកាលីចាប់ត្រី ។ ថ្ងៃមួយរ៉ាអៃរីបាននិយាយថា « តោះ យើងអធិស្ឋានដើម្បីយើងអាចមានសុវត្ថិភាព និងចាប់បានត្រីច្រើន » ។ ថ្ងៃនោះកាលីចាប់បានត្រីច្រើនជាងថ្ងៃមុនៗ ! កាលីបានសម្រេចចិត្តអធិស្ឋានជានិច្ចមុនពេលគាត់ទៅរកត្រី ។

រ៉ាអៃរីកំពុងតែរៀបចំខ្លួនទទួលពិធីបុណ្យជ្រមុជទឹក ។ គាត់បានប្រាប់កាលីអំពីរឿងនេះ ។ បន្ទាប់មកពួកអ្នកផ្សព្វផ្សាយសាសនាបានមក ហើយបានបង្រៀនកាលី និងមៃអំពីដំណឹងល្អ ។ ពេលដែលកាលី និងមៃទទួលបុណ្យជ្រមុជទឹក រ៉ាអៃរីបាននៅទីនោះ ។ គាត់បាននិយាយថា « ខ្ញុំសប្បាយចិត្តណាស់ដែលកាលីចង់ដើរតាមព្រះបាទារបស់ព្រះយេស៊ូវ » ។





រ៉ាអៃរី និងកាលី និងត្រីមួយចំនួនដែលពួកគេចាប់បាន ។

រ៉ាអៃរីបានធ្វើតាមព្រះយេស៊ូវ ដោយការជួយដល់កាលី និងមៃរៀនអំពីដំណឹងល្អ ។ សូមបើកទំព័រដើម្បីអានរឿងមួយអំពីរបៀបដែលព្រះយេស៊ូវបានជួយអ្នកដទៃ ។

## ចំណង់ចំណូលចិត្តរបស់រ៉ាអៃរី





**ទីកន្លែង ៖** ផ្ទះរបស់ម៉ាមី

**រឿងអំពីព្រះយេស៊ូវ ៖** នៅពេលដែលទ្រង់បានប្រទានអាហារដល់ហ្វូងមនុស្សជាមួយត្រីពីរ និងនំប៉័ងប្រាំដុំ

**ចម្រៀងកុមារ ៖** “I Know That My Savior Loves Me” ( Friend ខែ មីនា ឆ្នាំ ២០១៥ )

**អាហារ ៖** សាស៊ីមី ដែលធ្វើជាមួយត្រីស្រស់មកពីសមុទ្រ និងនំសូកូឡាចេញពីរូបមន្តរបស់លោកតាលោកយាយទួតរបស់គាត់

**ពណ៌ ៖** ក្រហម

**មុខវិជ្ជានៅសាលា ៖** គណិតវិទ្យា

> « សូមយើងដាក់សេចក្ដីជំនឿរបស់យើងលើព្រះអម្ចាស់ ព្រះយេស៊ូវគ្រីស្ទទៅជាសកម្មភាពផង ! »
>
> ប្រធាន រ័សុល អិម ណិលសុន « Opening the Heavens for Help » *Ensign* ឬ *Liahona* ខែ ឧសភា ឆ្នាំ២០២០ ទំព័រ ៧៣ ។